**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យ ឧ.ស.ហ.វ.
ចូលថ្ងៃទី 4/10/18 ម៉ោង..........
លេខ: 1818 0 9208

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន**
**សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

លេខ ២៩០

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម និង ផែនការអនុវត្តគម្រោង FMIS

នៅថ្ងៃអង្គារ ៩កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ម៉ោង ០៩:០០ នាទីព្រឹក នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរៀបចំកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម និង ផែនការអនុវត្តគម្រោង FMIS នៅដំណាក់កាលបន្តបន្ទាប់ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ, ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ, ឯកឧត្តមអគ្គលេខាធិការ អគ្គនាយក អគ្គាធិការ នាយកវិទ្យាស្ថាន, លោក លោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត, លោក លោកស្រីប្រធានរតនាគាររាជធានី-ខេត្ត និង សមាជិកនៃក្រុមការងារគ្រប់គ្រងគម្រោង FMIS នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គោលបំណង នៃការប្រជុំនេះ គឺ ដើម្បីពិនិត្យលើវឌ្ឍនភាព, បញ្ហាប្រឈមនានា និង ជាពិសេសការបង្ហាញឱ្យកាន់តែច្បាស់ និង ស៊ីជម្រៅ ជូនថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីសមិទ្ធផលធំៗដែលទទួលបានពីការអនុវត្តប្រព័ន្ធ FMIS ដែលបានដាក់ឱ្យអនុវត្តតាំងពីជំហានទី១ និង ទទួលបានជោគជ័យជាបន្តបន្ទាប់រហូតឈានដល់ការបន្តអនុវត្តគម្រោង FMIS ជំហានទី២ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធ FMIS តាំងពីដើមឆ្នាំ ២០១៧ កន្លងមក។ ក្នុងរបាយការណ៍នេះ បានបង្ហាញពីបញ្ហាប្រឈម វឌ្ឍនភាព និង សមិទ្ធផលគន្លឹះៗ នានាដែលកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នារបស់ក្រុមការងារគ្រប់គ្រងគម្រោង FMIS អស់រយៈពេលជាង ៤ ឆ្នាំ។

នៅក្នុងកិច្ចប្រជុំ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានធ្វើការសរុបអំពីបញ្ហាប្រឈម វឌ្ឍនភាព ក៏ដូចជាសមិទ្ធផលគន្លឹះៗជារួម ដូចតទៅ÷

១. ការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ក្នុងក្របខណ្ឌតំបន់ កម្ពុជាបានដើរឈានមុខប្រទេស វៀតណាម, ឡាវ, មីយ៉ាន់ម៉ា, ហ្វីលីពីន និង ឥណ្ឌូនេស៊ី។

២. ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រតនាគាររាជធានី-ខេត្តទាំង ២៥, ក្រសួងចំនួន ១០ និង អង្គភាពថវិកាផ្ទេរសិទ្ធិពេញលេញចំនួន ១១ និង កំពុងបន្តពង្រីកដាក់ឱ្យអនុវត្តទៅកាន់ក្រសួង-ស្ថាប័នចំនួន ១០ បន្ថែម និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងដើមឆ្នាំ ២០១៩។

៣. ការទូទាត់តាម "ប្រព័ន្ធបង្វែរទូទាត់អេឡិកត្រូនិក ( EFT-Electronic Fund Transfer)" ត្រូវបានដាក់ឱ្យដំណើរការ និង កំពុងឈានឆ្ពោះទៅការជំនួសមូលប្បទានបត្រ (Cheque) និង ការបង្វែរការទូទាត់ចំណាយផ្សេងទៀតទាំងស្រុង។

ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ÷ ៨៥៥ ២៣ ៤៣០០៦៣ ទូរសារ÷៨៥៥ ២៣ ៤៣០០៦៣
Phone : 855-23-430 063 Fax : 855-23-430 063

៤. ចំណាត់ថ្នាក់ទាំង ៧ នៃមាតិកាថវិកា ត្រូវបានដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធ FMIS ប៉ុន្តែមានចំណាត់ថ្នាក់តែចំនួន ៤ ប៉ុណ្ណោះ (សេដ្ឋកិច្ច, រដ្ឋបាល, កម្មវិធី និង គម្រោង) ដែលត្រូវបានអនុវត្តពេញលេញរហូតមកដល់ពេលនេះ ហើយចំណាត់ថ្នាក់ផ្សេងទៀតកំពុងបន្តជំរុញឱ្យអនុវត្ត។

៥. ការអនុវត្តប្រព័ន្ធ FMIS បច្ចុប្បន្នបានក្លាយជាការបន្ថែមបន្ទុកការងារដល់មន្ត្រី ដោយសារតែតម្រូវឱ្យអនុវត្តការងារក្នុងប្រព័ន្ធផង និង អនុវត្តការងារខាងក្រៅប្រព័ន្ធដោយប្រើប្រាស់ក្រដាសស្នាមផង ដែលបញ្ហានេះត្រូវការស្នើសុំគោលការណ៍ដើម្បីចាប់ផ្តើមសិក្សា ពិភាក្សា និង កាត់សម្រួលនីតិវិធីអនុវត្តការងារដែលពុំផ្តល់តម្លៃបន្ថែមនៅក្រៅប្រព័ន្ធ។

៦. សមត្ថភាពរបស់មន្ត្រីប្រើប្រាស់ប្រព័ន្ធ FMIS នៅមានកម្រិតនៅឡើយលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និង ហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែទោះជាយ៉ាងណា ក្រុមការងារបាននិងកំពុងរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់។

៧. ផែនការគ្រប់គ្រងការផ្លាស់ប្តូរ ទាមទារឱ្យមានការរៀបចំឱ្យបានច្បាស់លាស់ក្នុងការផ្លាស់ប្តូរតួនាទីភារកិច្ចរបស់មន្ត្រី និង ស្ថាប័នដែលប៉ះពាល់ និង ពុំទាន់មាន។

កិច្ចប្រជុំបានពិនិត្យ និង ពិភាក្សាលើវឌ្ឍនភាព បញ្ហាប្រឈម និង ផែនការអនុវត្តគម្រោង FMIS និងបានសម្រេចតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ដូចខាងក្រោម÷

១. ស្នើអគ្គនាយកដ្ឋានរតនាគារជាតិ ដោះស្រាយបញ្ហាបច្ចេកទេសក្នុងប្រព័ន្ធ និង គុណភាពទិន្នន័យ ដើម្បីធានាឱ្យបាននូវការបិទបញ្ជីប្រចាំឆ្នាំ ២០១៨ នៅឆ្នាំ ២០១៩ តាមប្រព័ន្ធ FMIS ដោយមិនចាំបាច់ត្រូវផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ខាងក្រៅ និង ប្រសិនមានការបើកការិយបរិច្ឆេទឆ្លងឆ្នាំ គឺត្រូវតែបិទបញ្ជីភ្លាមៗបន្ទាប់ពីបញ្ចប់ការបើកការិយបរិច្ឆេទនោះ។

២. ស្នើឱ្យគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធ ពិសេសអគ្គនាយកដ្ឋានថវិកា និង អគ្គនាយកដ្ឋានរតនាគារជាតិ សហការបន្តពិភាក្សាដោះស្រាយជាមួយគ្នាដើម្បីឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង៧ ឱ្យបានពេញលេញ ហើយមុនពេលចេញជាសារាចរ ឬការណែនាំផ្សេងៗត្រូវមានការពិភាក្សាគ្នាឱ្យលម្អិត និង ជិតស្និទ្ធបំផុតជាមួយក្រុមការងារគ្រប់គ្រងគម្រោង FMIS ដើម្បីជៀសវាងការមិនព្រមព្រៀង ឬមិនឯកភាពគ្នាលើប្រការណាមួយ។

៣. ស្នើឱ្យក្រុមការងារពាក់ព័ន្ធក្រោមការដឹកនាំសម្របសម្រួលដោយក្រុមការងារគ្រប់គ្រងគម្រោង FMIS ក្នុងការរៀបចំកាត់បន្ថយនីតិវិធីអនុវត្តការងារធ្វើដោយដៃ និង ឈានទៅអនុវត្តនីតិវិធីអនុវត្តការងារក្នុងប្រព័ន្ធ FMIS ទាំងស្រុងដោយត្រូវគិតគូរដោយត្រូវឈរលើមូលដ្ឋានដូចខាងក្រោម÷

- គិតគូរការអនុវត្តពីក្រសួង-ស្ថាប័នដែលបានចូលប្រើប្រាស់ប្រព័ន្ធ FMIS និង បញ្ចូលព័ត៌មាន ឬ ទិន្នន័យពីដំបូងហើយបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធ្វើការសម្រេច ឬ អនុម័តនៅក្នុងប្រព័ន្ធ FMIS
- កំណត់ឱ្យបានច្បាស់អំពីនីតិវិធីចំណាយណាខ្លះដែលត្រូវធ្វើការកែសម្រួល
- ផ្តោតលើអភិក្រមពិនិត្យមើលលើមុខចំណាយដែលមានហានិភ័យទាប (Low Risk) ឬ មិនមានហានិភ័យនៅក្នុងការចាយខុស ឬ ប្រសិទ្ធភាពនៃកិច្ចការចំណាយដោយធ្វើការសម្រេចតាមប្រព័ន្ធ ដូចជាចំណាយថ្លៃទឹក, ថ្លៃអគ្គិសនី និង ប្រាក់ខែ ជាដើម ចំពោះផ្នែកមានចំណាយដែលមានហានិភ័យខ្ពស់ (High Risk) ដែលត្រូវការមើលក្រោយបន្ថែម ក៏នឹងត្រូវយកមកសិក្សាដើម្បីកាត់បន្ថយជាបណ្តើរៗនាពេលអនាគត
- តាមមុខចំណាយដែលមានហានិយភ័យតិចតួច ដូចជាចំណាយថ្លៃទឹក, ថ្លៃអគ្គិសនី និង ប្រាក់ខែ ជាដើម និង បន្តអនុវត្តលើមុខចំណាយផ្សេងៗទៀតជាបន្តបន្ទាប់នាពេលអនាគត

- ត្រូវគិតគូរលើការរៀបចំវគ្គបណ្តុះបណ្តាល និង ការរៀបចំដាក់ពង្រាយមន្ត្រីទៅតាមមុខងារថ្មីនៃប្រព័ន្ធ FMIS ឬនីតិវិធីអនុវត្តការងារថ្មី ដែលការងារទាំងនេះ គឺត្រូវរៀបចំនូវផែនការគ្រប់គ្រងការផ្លាស់ប្តូរ (Change Management Plan) ច្បាស់លាស់ ពីពេលនេះរហូតដល់ឆ្នាំ ២០២០។

៤. សម្រេចជ្រើសរើសមុខងារបន្ថែមថ្មីចំនួន ២ ដែលត្រូវសិក្សា និង អភិវឌ្ឍសម្រាប់ប្រព័ន្ធ FMIS ក្នុងឆ្នាំ២០១៩ ÷

- **មុខងាររៀបចំផែនការថវិកា** ដែលជាមុខងារចាំបាច់មួយក្នុងការរៀបចំផែនការថវិកាក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីឱ្យមានសង្គតិភាពជាមួយការអនុវត្តចំណាយថវិកាក្នុងប្រព័ន្ធ និង មិនមានភាពរអាក់រអួលតាំងពីដើមទីមក
- **មុខងារលទ្ធកម្ម** ព្រោះជាមុខងារសំខាន់ក្នុងខួបនៃចំណាយថវិកា ហើយដែលត្រូវគិតគូរឱ្យស្របតាមការធ្វើសុខដុមនីយកម្មរវាងលទ្ធកម្មចំណាយរបស់រដ្ឋាភិបាល និង ចំណាយរបស់ថវិកាដៃគូក្នុងគោលដៅសម្រេចឱ្យបាននៅឆ្នាំ ២០២៥ កម្ពុជាមានប្រព័ន្ធលទ្ធកម្មជាតិតែមួយ តែសូមរក្សាឱ្យមានភាពទន់ភ្លន់អាចសម្រប-សម្រួលក្នុងការអនុវត្តជាមួយដៃគូអភិវឌ្ឍន៍បាន

  ការងារខាងលើនេះ ត្រូវធ្វើក្នុងបរិការនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ និង ការកែទម្រង់ប្រព័ន្ធលទ្ធកម្ម ដែលនៅឆ្នាំ២០២៥ គឺត្រូវមានប្រព័ន្ធលទ្ធកម្មជាតិតែមួយ។

៥. ដោយឡែកសម្រាប់មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង មុខងារគ្រប់គ្រងសន្និធិ គួររៀបចំអភិវឌ្ឍនៅពេលក្រោយ ហើយប្រព័ន្ធចំណូលមិនមែនសារពើពន្ធ (Non-Tax System) ត្រូវត្រៀមរៀបចំធ្វើសន្ធានកម្មជាមួយប្រព័ន្ធ FMIS នៅពេលអនាគត ឬ ត្រូវប្រើប្រាស់ប្រព័ន្ធ FMIS តែម្តងនៅពេលមុខងារនេះត្រូវបានដាក់ឱ្យដំណើរការ។

៦. ស្នើគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធក្នុងការអនុវត្តគម្រោង FMIS សហការគ្នាពិនិត្យពីភាពសមស្របលើការងារកែទម្រង់ប្រព័ន្ធថវិកា និង ប្រព័ន្ធលទ្ធកម្ម ហើយត្រូវពិនិត្យលើមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការផ្លាស់ប្តូរមុខងារ, តួនាទី, សិទ្ធិអំណាចក្នុងការអនុវត្តថវិកា និង សិទ្ធិក្នុងការប្រើប្រាស់ប្រព័ន្ធ ក៏ដូចជាកំណត់ការដ្ឋានឱ្យបានច្បាស់លាស់ដល់មន្ត្រីហិរញ្ញវត្ថុក្នុងការប្រើប្រាស់ប្រព័ន្ធ។

៧. ស្នើអគ្គនាយកដ្ឋានថវិកា ត្រួតពិនិត្យលើការបង្កើតក្រុមការងារថវិកា (អភិបាលថវិកា) នៅតាមក្រសួង-ស្ថាប័ននាពេលអនាគតឱ្យសមស្របជាមួយក្រសួង-ស្ថាប័នណាដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីឱ្យមានសង្គតិភាពជាកញ្ចប់ជាមួយការអនុវត្តគម្រោង FMIS និង ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

៨. ស្នើឱ្យក្រុមការងារគ្រប់គ្រងគម្រោងបន្តធ្វើការកែលម្អកម្មវិធីកញ្ចក់ថវិកា (Budget Mirror) បន្ថែមឱ្យបានស្អាត និងរៀបចំដាក់ឱ្យប្រើប្រាស់នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ពោលគឺចាប់ពីថ្នាក់ដឹកនាំកម្រិតត្រឹមអគ្គនាយក-ដ្ឋានដែលមានការពាក់ព័ន្ធរវាងកម្មវិធី និង មុខងាររបស់ខ្លួន។ ដោយឡែកសម្រាប់ថ្នាក់ដឹកនាំកម្រិតអនុរដ្ឋលេខាធិការឡើង ចាំបាច់ត្រូវប្រើប្រាស់ដើម្បីដឹងពីការងាររួម និង ទាញយករបាយការណ៍ ដូចនេះក្រុមការងារត្រូវរៀបចំបង្ហាញដាច់ដោយឡែកមួយជាមួយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និង សម្រេចលើកម្រិតព័ត៌មាន និង កម្រិតថ្នាក់ដឹកនាំដែលត្រូវប្រើប្រាស់កម្មវិធីនេះ។

ចុងបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានកោតសរសើរ និង លើកទឹកចិត្ត ដល់ក្រុមការងារគ្រប់គ្រងគម្រោង FMIS និង អគ្គនាយកដ្ឋានពាក់ព័ន្ធទាំងអស់ ឱ្យបន្តសហការគ្នាឱ្យបានជិតស្និទ្ធបំផុត ក្នុងការអនុវត្តគម្រោង

FMIS ដែលជាមូលដ្ឋានគន្លឹះសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ជាឆ្អឹងខ្នងក្នុងការងារកែទម្រង់ប្រព័ន្ធថវិកាថ្មី។

អង្គប្រជុំបានបញ្ចប់នៅថ្ងៃដដែល វេលាម៉ោង ១១:៣០ នាទីព្រឹក ប្រកបដោយបរិយាកាសស្និទ្ធស្នាលបំផុត។

ថ្ងៃ អង្គារ ១រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៨

**អ្នកធ្វើរបាយការណ៍**

**ឈាង យូ**

បានឃើញ និង ឯកភាព
សូមគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ពិនិត្យ និង សម្រេច
ថ្ងៃ អង្គារ ៨រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៨

**រដ្ឋលេខាធិការ និងជា**

**ប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS**

ហ៊ាន សាហ៊ីប

.................................................................
ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# សេចក្តីសម្រេច

## កិច្ចប្រជុំពិនិត្យលើវឌ្ឍនភាព បញ្ហាប្រឈម និង ផែនការអនុវត្តគម្រោង FMIS

លទ្ធផលនៃកិច្ចប្រជុំពិនិត្យលើវឌ្ឍភាព បញ្ហាប្រឈម និង ផែនការអនុវត្តគម្រោង FMIS កាលពីថ្ងៃអង្គារ ៩កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨ ម៉ោង ០៩:០០ នាទីព្រឹក បានដាក់ចេញសេចក្តីសម្រេច ដើម្បីយកទៅអនុវត្តដូចខាងក្រោម÷

១. ស្នើអគ្គនាយកដ្ឋានរតនាគារជាតិ ដោះស្រាយបញ្ហាបច្ចេកទេសក្នុងប្រព័ន្ធ និង គុណភាពទិន្នន័យ ដើម្បីធានាឱ្យបាននូវការបិទបញ្ជីប្រចាំឆ្នាំ ២០១៨ នៅឆ្នាំ ២០១៩ តាមប្រព័ន្ធ FMIS ដោយមិនចាំបាច់ត្រូវផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ខាងក្រៅ និង ប្រសិនមានការបើកការិយបរិច្ឆេទឆ្លងឆ្នាំ គឺត្រូវតែបិទបញ្ជីភ្លាមៗបន្ទាប់ពីបញ្ចប់ការបើកការិយបរិច្ឆេទនោះ។

២. ស្នើឱ្យគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធ ពិសេសអគ្គនាយកដ្ឋានថវិកា និង អគ្គនាយកដ្ឋានរតនាគារជាតិ សហការបន្តពិភាក្សាដោះស្រាយជាមួយគ្នាដើម្បីឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង៧ ឱ្យបានពេញលេញ ហើយមុនពេលចេញជាសារាចរ ឬការណែនាំផ្សេងៗត្រូវមានការពិភាក្សាគ្នាឱ្យលម្អិត និង ជិតស្និទ្ធបំផុតជាមួយក្រុមការងារគ្រប់គ្រងគម្រោង FMIS ដើម្បីជៀសវាងការមិនព្រមព្រៀង ឬមិនឯកភាពគ្នាលើប្រការណាមួយ។

៣. ស្នើឱ្យក្រុមការងារពាក់ព័ន្ធក្រោមការដឹកនាំសម្របសម្រួលដោយក្រុមការងារគ្រប់គ្រងគម្រោង FMIS ក្នុងការរៀបចំកាត់បន្ថយនីតិវិធីអនុវត្តការងារធ្វើដោយដៃ និង ឈានទៅអនុវត្តនីតិវិធីអនុវត្តការងារក្នុងប្រព័ន្ធ FMIS ទាំងស្រុង ដោយត្រូវគិតគូរដោយត្រូវឈរលើមូលដ្ឋានដូចខាងក្រោម÷

- គិតគូរការអនុវត្តពីក្រសួង-ស្ថាប័នដែលបានចូលប្រើប្រាស់ប្រព័ន្ធ FMIS និង បញ្ចូលព័ត៌មាន ឬ ទិន្នន័យពីដំបូង ហើយបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធ្វើការសម្រេច ឬ អនុម័តនៅក្នុងប្រព័ន្ធ FMIS
- កំណត់ឱ្យបានច្បាស់អំពីនីតិវិធីចំណាយណាខ្លះដែលត្រូវធ្វើការកែសម្រួល
- ផ្តោតលើអភិក្រមពិនិត្យមើលលើមុខចំណាយដែលមានហានិភ័យទាប (Low Risk) ឬ មិនមានហានិភ័យនៅក្នុងការចាយខុស ឬ ប្រសិទ្ធភាពនៃកិច្ចការចំណាយដោយធ្វើការសម្រេចតាមប្រព័ន្ធ ដូចជាចំណាយថ្លៃទឹក, ថ្លៃអគ្គិសនី និង ប្រាក់ខែ ជាដើម ចំពោះផ្នែកមានចំណាយដែលមានហានិភ័យខ្ពស់ (High Risk) ដែលត្រូវការមើលក្រៅបន្ថែម ក៏នឹងត្រូវយកមកសិក្សាដើម្បីកាត់បន្ថយជាបណ្តើរៗនាពេលអនាគត
- តាមមុខចំណាយដែលមានហានិយភ័យតិចតួច ដូចជាចំណាយថ្លៃទឹក, ថ្លៃអគ្គិសនី និង ប្រាក់ខែ ជាដើម និង បន្តអនុវត្តលើមុខចំណាយផ្សេងៗទៀតជាបន្តបន្ទាប់នាពេលអនាគត
- ត្រូវគិតគូរលើការរៀបចំវគ្គបណ្តុះបណ្តាល និង ការរៀបចំដាក់ពង្រាយមន្ត្រីទៅតាមមុខងារថ្មីនៃប្រព័ន្ធ FMIS ឬនីតិវិធីអនុវត្តការងារថ្មី ដែលការងារទាំងនេះ គឺត្រូវរៀបចំនូវផែនការគ្រប់គ្រងការផ្លាស់ប្តូរ (Change Management Plan) ច្បាស់លាស់ ពីពេលនេះរហូតដល់ឆ្នាំ ២០២០។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៤. សម្រេចជ្រើសរើសមុខងារបន្ថែមថ្មីចំនួន ២ ដែលត្រូវសិក្សា និង អភិវឌ្ឍសម្រាប់ប្រព័ន្ធ FMIS ក្នុងឆ្នាំ២០១៩ ÷

- **មុខងាររៀបចំផែនការថវិកា** ដែលជាមុខងារចាំបាច់មួយក្នុងការរៀបចំផែនការថវិកាក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដើម្បីឱ្យមានសង្គតិភាពជាមួយការអនុវត្តចំណាយថវិកាក្នុងប្រព័ន្ធ និង មិនមានភាពរអាក់រអួលតាំងពីដើមទីមក
- **មុខងារលទ្ធកម្ម** ព្រោះជាមុខងារសំខាន់ក្នុងខួបនៃចំណាយថវិកា ហើយដែលត្រូវគិតគូរឱ្យស្របតាមការធ្វើសុខដុមនីយកម្មរវាងលទ្ធកម្មចំណាយរបស់រដ្ឋាភិបាល និង ចំណាយរបស់ថវិកាដៃគូក្នុងគោលដៅសម្រេចឱ្យបាននៅឆ្នាំ ២០២៥ កម្ពុជាមានប្រព័ន្ធលទ្ធកម្មជាតិតែមួយ តែសូមរក្សាឱ្យមានភាពទន់ភ្លន់អាចសម្របសម្រួលក្នុងការអនុវត្តជាមួយដៃគូអភិវឌ្ឍន៍បាន

ការងារខាងលើនេះ ត្រូវធ្វើក្នុងបរិការនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ និង ការកែទម្រង់ប្រព័ន្ធលទ្ធកម្ម ដែលនៅឆ្នាំ២០២៥ គឺត្រូវមានប្រព័ន្ធលទ្ធកម្មជាតិតែមួយ។

៥. ដោយឡែកសម្រាប់មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង មុខងារគ្រប់គ្រងសន្និធិ គួររៀបចំអភិវឌ្ឍនៅពេលក្រោយ ហើយប្រព័ន្ធចំណូលមិនមែនសារពើពន្ធ (Non-Tax System) ត្រូវត្រៀមរៀបចំធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS នៅពេលអនាគត ឬ ត្រូវប្រើប្រាស់ប្រព័ន្ធ FMIS តែម្តងនៅពេលមុខងារនេះត្រូវបានដាក់ឱ្យដំណើរការ។

៦. ស្នើគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធក្នុងការអនុវត្តគម្រោង FMIS សហការគ្នាពិនិត្យពីភាពសមស្របលើការងារកែទម្រង់ប្រព័ន្ធថវិកា និង ប្រព័ន្ធលទ្ធកម្ម ហើយត្រូវពិនិត្យលើមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការផ្លាស់ប្តូរមុខងារ, តួនាទី, សិទ្ធិអំណាចក្នុងការអនុវត្តថវិកា និង សិទ្ធិក្នុងការប្រើប្រាស់ប្រព័ន្ធ ក៏ដូចជាកំណត់ការដ្ឋានឱ្យបានច្បាស់លាស់ដល់មន្ត្រីហិរញ្ញវត្ថុក្នុងការប្រើប្រាស់ប្រព័ន្ធ។

៧. ស្នើអគ្គនាយកដ្ឋានថវិកា ត្រួតពិនិត្យលើការបង្កើតក្រុមការងារថវិកា (អភិបាលថវិកា) នៅតាមក្រសួង-ស្ថាប័ននាពេលអនាគតឱ្យសមស្របជាមួយក្រសួង-ស្ថាប័នណាដែលបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS ដើម្បីឱ្យមានសង្គតិភាពជាកញ្ចប់ជាមួយការអនុវត្តគម្រោង FMIS និង ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

៨. ស្នើឱ្យក្រុមការងារគ្រប់គ្រងគម្រោងបន្តធ្វើការកែលម្អកម្មវិធីកញ្ចក់ថវិកា (Budget Mirror) បន្ថែមឱ្យបានស្អាត និងរៀបចំដាក់ឱ្យប្រើប្រាស់នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ពោលគឺចាប់ពីថ្នាក់ដឹកនាំកម្រិតត្រឹមអគ្គនាយកដ្ឋានដែលមានការពាក់ព័ន្ធរវាងកម្មវិធី និង មុខងាររបស់ខ្លួន។ ដោយឡែកសម្រាប់ថ្នាក់ដឹកនាំកម្រិតអនុរដ្ឋលេខាធិការឡើង ចាំបាច់ត្រូវប្រើប្រាស់ដើម្បីដឹងពីការងាររួម និង ទាញយករបាយការណ៍ ដូចនេះក្រុមការងារត្រូវរៀបចំបង្ហាញដាច់ដោយឡែកមួយជាមួយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ក្នុងការពិនិត្យ និង សម្រេចលើកម្រិតព័ត៌មាន និង កម្រិតថ្នាក់ដឹកនាំដែលត្រូវប្រើប្រាស់កម្មវិធីនេះ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**